**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
**គណៈកម្មការរៀបចំការប្រឡងប្រជែង**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការទទួលសាធារណជនចុះឈ្មោះជាអ្នកសង្កេតការណ៍ក្នុងដំណើរការប្រឡងប្រជែង ជ្រើសរើសគ្រូបង្រៀន សម្រាប់បង្រៀននៅអនុវិទ្យាល័យ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួងអប់រំ យុវជន និងកីឡា វិញ្ញាសាសរសេរលើកទី២

គណៈកម្មការរៀបចំការប្រឡងប្រជែងសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន សម្រាប់បង្រៀននៅអនុវិទ្យាល័យ ឱ្យចូលបម្រើការងារនៅក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា វិញ្ញាសាសរសេរលើកទី២ នឹងប្រព្រឹត្តទៅនៅ**ថ្ងៃសៅរ៍ ទី១៨ ខែឧសភា ឆ្នាំ២០២៤** នៅមណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងនៅមណ្ឌលកំណែសាលាភូមិន្ទរដ្ឋបាលនាថ្ងៃបន្តបន្ទាប់។

ដើម្បីជាការបង្ហាញឱ្យឃើញពិតប្រាកដថា ការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន សម្រាប់បង្រៀននៅអនុវិទ្យាល័យ ឱ្យចូលបម្រើការងារនៅក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ប្រព្រឹត្តទៅប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព គណៈកម្មការរៀបចំការប្រឡងប្រជែង បានអនុញ្ញាតឱ្យសាធារណជនស្ម័គ្រចិត្តចំនួន **២០នាក់** ដាក់ពាក្យស្នើសុំចូលរួមសង្កេតការណ៍ដោយផ្ទាល់នៅមណ្ឌលប្រឡង និងមណ្ឌលកំណែ តាមកាលបរិច្ឆេទ និងទីតាំងដូចបានបញ្ជាក់ជូនខាងលើ។

**អ្នកសង្កេតការណ៍ជាសាធារណជន** នឹងត្រូវបានអញ្ជើញឱ្យតាមដានដំណើរការប្រឡងប្រជែង ចាប់តាំងពីពេលរៀបចំវិញ្ញាសា (ពេលព្រឹក) រហូតដល់ពេលចាប់ផ្តើមប្រឡងនាម៉ោង១២:៣០នាទីថ្ងៃត្រង់តទៅ។ **អ្នកសង្កេតការណ៍ជាសាធារណជន** ក៏ត្រូវចូលរួមសម្រាប់ដំណើរការកំណែនៅមណ្ឌលកំណែសាលាភូមិន្ទរដ្ឋបាល នាថ្ងៃបន្តបន្ទាប់ រហូតដល់ដំណើរការប្រឡងប្រជែងត្រូវបញ្ចប់ជាស្ថាពរ។

សាធារណជនអាចដាក់ពាក្យតាមរយៈ QR Code ឬ Link **ចាប់ពីថ្ងៃផ្សាយដំណឹងរហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ ត្រឹមម៉ោង១២:០០ថ្ងៃត្រង់។**

<u>**សូមបញ្ជាក់៖**</u> អ្នកដាក់ពាក្យចំនួន២០នាក់ដំបូងដែលបានបំពេញព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់នឹងត្រូវបានជ្រើសរើសធ្វើជា**អ្នកសង្កេតការណ៍ជាសាធារណជន**។

ថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២៤
**គណៈកម្មការរៀបចំការប្រឡងប្រជែង**

ស្កេនទីនេះ

https://forms.gle/Li7CG8RuPSHKzvpw6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
គណៈកម្មការរៀបចំការប្រឡងប្រជែង

# បទបញ្ញត្តិ

## សម្រាប់អ្នកសង្កេតការណ៍ក្នុងដំណើរការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន សម្រាប់បង្រៀន នៅអនុវិទ្យាល័យ ឱ្យចូលបម្រើការងារនៅក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម័យប្រឡង ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤

ដើម្បីឱ្យការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន សម្រាប់បង្រៀននៅអនុវិទ្យាល័យ ឱ្យចូលបម្រើការងារនៅក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា វិញ្ញាសាសរសេរលើកទី២ ប្រព្រឹត្តទៅប្រកបដោយ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន ប្រសិទ្ធភាព គណៈកម្មការរៀបចំការប្រឡងប្រជែងសូមដាក់ចេញនូវបទបញ្ញត្តិ សម្រាប់អ្នកចូលរួមសង្កេតការណ៍ដូចខាងក្រោម៖

**១/ សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍**

- មានសិទ្ធិចូលទៅសង្កេតការណ៍ដល់អគារប្រឡង និងនៅខាងក្រៅបន្ទប់ប្រឡង
- ត្រូវប្រើឯកសណ្ឋានសម្គាល់ស្ថាប័នបំពេញការងារ ឬសំលៀកបំពាក់សមរម្យ និងពាក់កាតសម្គាល់ខ្លួនត្រឹមត្រូវ
- ត្រូវប្រតិបត្តិតាមការណែនាំរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង
- ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ ស្របតាមច្បាប់ លិខិតបទដ្ឋាន និងបទបញ្ញត្តិដទៃទៀត
- ធានាថា សកម្មភាពសង្កេតការណ៍របស់ខ្លួន មិនបង្កការរំខានដល់មន្ត្រីរៀបចំការប្រឡង និងបេក្ខជន
- ក្នុងករណីសង្កេតឃើញ ឬយល់ឃើញថា មានសកម្មភាពណាមួយមិនប្រក្រតី ត្រូវរាយការណ៍មកអនុគណៈកម្មការដែលគ្រប់គ្រងអ្នកសង្កេតការណ៍ភ្លាម ដើម្បីមានចំណាត់ការសមស្រប
- អាចផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងដំណើរការនៃការប្រឡងប្រជែង ដល់គណៈកម្មការរៀបចំការប្រឡងប្រជែង។

**២/ បម្រាមចំពោះអ្នកសង្កេតការណ៍**

- ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង
- ជជែកពិភាក្សា ឬផ្តល់សំណៅឯកសារផ្សេងៗដល់បេក្ខជននៅក្នុងបរិវេណមណ្ឌលប្រឡង
- មិនអនុញ្ញាតឱ្យយកទូរស័ព្ទ ឬគ្រឿងអេឡិចត្រូនិច ថតរូប ថតវីដេអូ ឬថតសំឡេងនៅក្នុងបរិវេណមណ្ឌលប្រឡងឡើយ
- សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ដោយគ្មានការអនុញ្ញាត
- យកតាមខ្លួននូវអាវុធ ឬជាតិផ្ទុះ ឬវត្ថុដែលអាចបង្កគ្រោះថ្នាក់ចូលមណ្ឌលប្រឡង
- រំលោភទៅលើបទបញ្ញត្តិទាំងឡាយនៃការប្រឡងប្រជែង។

◀ ក្នុងករណីអ្នកសង្កេតការណ៍មិនអនុវត្តតាមបទបញ្ញត្តិ ឬការណែនាំរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង អ្នកសង្កេតការណ៍នោះនឹងត្រូវបណ្តេញចេញពីមណ្ឌលប្រឡង និង/ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។